សុខ ចាន់ផល

ខ្ញុំខំស្វែងយល់ពីកំណើតខ្លួនឯង... តើខ្ញុំកើតមកធ្វើអី?
ខ្ញុំត្រូវទ្រាំចាំពេលវេលា ត្រូវទ្រាំរស់ក្នុងអារម្មណ៍ភ័យខ្លាច
ត្រូវដោះស្រាយបញ្ហាស្ទើរគ្មានពេលសម្រាក...
ដោះស្រាយធ្វើអីទៅ?

# ស្រមោលខ្មៅ



សមាគមសេរីភាព
LIBERTY ASSOCIATION

សុខ ចាន់ផល

# ស្រមោលខ្មៅ

២០១២

សមាគមសេរីភាព
LIBERTY ASSOCIATION

បោះពុម្ពផ្សាយដោយ សមាគមសេរីភាព
ផ្ទះលេខ ៥៣ CE0 ផ្លូវ ២៤២
សង្កាត់ចតុមុខ ខណ្ឌដូនពេញ ក្រុងភ្នំពេញ
ប្រទេសកម្ពុជា

Liberty Association
#53 CE0, St 242
Chaktomuk, Daun Penh, Phnom Penh
Cambodia

**Blog :** khmerphnompenh.wordpress.com

**Public relation :**
Davith Bolin
cambocanada@gmail.com

**ប្រធានសមាគម ៖** អ្នកស្រី កែ ផល្លា

**ផ្នែកបោះពុម្ពផ្សាយ ៖** អ្នកស្រី លឹម សន្តិភាព

**ផ្នែកនិពន្ធ ៖**

អ្នកនាង សិរី វឌ្ឍនា

លោក សុខ ចាន់ផល

កញ្ញា ណោង កន្និដ្ឋា

កញ្ញា អ៊ឹម រចនា

លោក ម៉ា ច័ន្ទបញ្ញា

កញ្ញា ម៉េង សិរីរចនា

**ផ្នែកអក្ខរាវិរុទ្ធ ៖** លោក ហេង ឧត្តម

**ផ្នែករៀបសាយ ៖** លោក ទឹម បឿន

**ផ្នែកទំនាក់ទំនងសាធារណៈ ៖** លោក បូលីន ដាវីដ

គ្រប់មាតិកានៃរឿងនេះជាកម្មសិទ្ធិបញ្ញា
របស់ **សុខ ចាន់ផល**។

នេះគឺជាសៀវភៅរឿងប្រលោមលោកបែបច្នៃប្រឌិត។ ឈ្មោះតួអង្គ ទីកន្លែង និង
ហេតុការណ៍តួអង្គនៅក្នុងសៀវភៅនេះ សុទ្ធតែជាការស្រមើស្រមៃ។

រាល់ព្រឹត្តិការណ៍ ដែលស្រដៀង ឬដូចគ្នាទៅនឹងភាពជាក់ស្តែង បុគ្គល
នៅរស់ ឬស្លាប់ និងទីកន្លែង ឬស្ថាប័ន គឺជាការចៃដន្យតែប៉ុណ្ណោះ។

ភ្លើងគោមនៅតាមផ្លូវភ្លឺចិញ្ចាច ប៉ុន្តែវានៅតែជាយប់ដ៏សែនងងឹត។ មនុស្សម្នាមាត់ឡូឡាគ្រប់ទីកន្លែង ប៉ុន្តែខ្ញុំនៅតែឯកោ។ ម៉ូតូឡានបើកស្ទើរតែបុកខ្ញុំ ប៉ុន្តែខ្ញុំហាក់កំពុងដើរលើផ្លូវមួយតែម្នាក់ឯង។ ភ្នែកខ្ញុំមិនមែនខ្វាក់ទេ។ ត្រចៀកខ្ញុំក៏មិនមែនថ្លង់ដែរ។ ប៉ុន្តែអារម្មណ៍ខ្ញុំទេ ដែលកំពុងតែខ្វាក់និងថ្លង់។ តើពេលនេះខ្ញុំកំពុងធ្វើអ្វី...? កំពុងដើរទៅណា? ខ្ញុំកំពុងដើរទៅផ្ទះដេក ព្រោះវាយប់ទៅហើយ។ ខ្ញុំនឹងដេកនៅពេលភពផែនដីងងឹត ហើយខ្ញុំនឹងក្រោកវិញនៅពេលព្រះអាទិត្យរះ។

ខ្ញុំសម្លឹងមើលមនុស្សនៅជុំវិញខ្លួន ដែលកំពុងអង្គុយកំពុងឈរ កំពុងដើរ កំពុងសើច កំពុងក្រៀមក្រំ... ខ្លួនប្រាណខ្ញុំ ដូងចិត្តខ្ញុំហាក់រលាយមើលមិនឃើញ រួចរសាត់តាមខ្យល់ហោះទៅលើអាកាស។ ប្រហែលខ្លួនប្រាណខ្ញុំរលាយសូន្យហើយ ទើបខ្ញុំចេះសម្លឹងជីវិតដោយដួងចិត្ត សម្លឹងមើលអ្នកដទៃដោយអារម្មណ៍សង្វេគ។ ខ្ញុំមានអារម្មណ៍ថាគ្មានមនុស្សណាម្នាក់មើលរូបខ្ញុំឃើញទេ ហើយទោះខ្ញុំចង់សួរគេថា តើពួកគេកំពុងធ្វើអ្វី? ក៏គ្មានអ្នកណាអាចឆ្លើយនឹងសំណួរខ្ញុំបានដែរ។

ខ្ញុំដើរមួយជំហានម្តងៗត្រឡប់ទៅផ្ទះ ផ្ទុយពីព្រឹកមិញដែលខ្ញុំដើរមួយជំហានម្តងៗ ចេញពីផ្ទះមករកការងារធ្វើ។ ពេញមួយថ្ងៃនេះខ្ញុំហូបតែនំប៉័ងមួយ និងផឹកតែទឹកម៉ាស៊ីនប៉ុន្មានក្អឹកប៉ុណ្ណោះ។ ខ្ញុំដឹងថាវាមិនល្អសម្រាប់សុខភាពទេ ប៉ុន្តែខ្ញុំគ្មានផ្លូវជ្រើសរើស។ ខ្ញុំដឹងថាបានជាគ្មានអ្នកណាព្រមទទួលខ្ញុំធ្វើការ ព្រោះរូបរាងខ្ញុំមិនស្អាត សម្លៀកបំពាក់ខ្ញុំមិនសមរម្យ។ ប៉ុន្តែតើឱ្យខ្ញុំធ្វើយ៉ាងម៉េច? ខ្ញុំលែងចេះធ្វើអ្វីហើយ! ខ្ញុំលែងចេះសូម្បីតែរស់...!

តើជីវិតខ្ញុំកើតមកសម្រាប់តែទទួលកម្មមែនទេ? ខ្ញុំក្រណាស់! ខ្ញុំគ្មានអ្វីទាំងអស់... បើមានគឺមានតែម្តាយម្នាក់ដែលគាត់មិនត្រឹមតែក្រដូចខ្ញុំទេ ថែមទាំងកំពុងតែឈឺទៀត! សូម្បីតែការងារដែលកំពុងតែធ្វើក៏ថៅកែរត់ចោល អត់បើកប្រាក់ខែឱ្យខ្ញុំដែរ។ ជីវិតពោរពេញដោយបាបរបស់ខ្ញុំ ធ្វើឱ្យខ្ញុំមិនហ៊ានស្រមៃក្លាយខ្លួនជាមហាសេដ្ឋីទេ ឱ្យតែមានប្រាក់ទិញបាយ និងទិញថ្នាំពន្យារជីវិតម្តាយក៏គ្រប់គ្រាន់ហើយ។ តាំងពីថ្ងៃដែលឪពុកខ្ញុំស្លាប់ ខ្ញុំមិនដែលប្រាថ្នាជីវិតសប្បាយរីករាយទេ។ ខ្ញុំប្រាថ្នាសុំតែមានជីវិតរស់នៅបន្តទៀតប៉ុណ្ណោះ ប៉ុន្តែគ្រាន់តែបំណងដ៏កំសាកមួយនេះ ក៏ខ្ញុំមិនអាចសម្រេចវាបានផង។

ទោះបីខ្ញុំមិនចង់ដើរលឿន មិនចង់ប្រញាប់ទៅដល់ផ្ទះ មិនចង់ឱ្យពេលវេលាដើរទៅមុខ ប៉ុន្តែគ្រប់យ៉ាងសុទ្ធតែខ្ញុំគ្មានអំណាចធ្វើបាន។ នៅសល់ប្រហែលជាបីគីឡូម៉ែត្រទៀតទេ ពេលវេលាប្រាកដជាអូសជំហានដ៏ល្វើយរបស់ខ្ញុំទៅដល់ខ្ទមមួយហើយ។ ខ្ញុំហាក់ដូចជាកំពុងដើរតាមផ្លូវទៅស្ថាននរក។ ខ្ញុំគ្មានអារម្មណ៍ខ្លាចស្ថាននរកទេ ព្រោះទោះជានៅស្ថានណាក៏ជីវិតខ្ញុំឯកោដូចគ្នា។ ពេលខ្ញុំសម្លឹងម្តាយខ្ញុំ ដែលកំពុងតែឈឺរង់ចាំថ្ងៃស្លាប់... ពេលខ្ញុំសម្លឹងមើលខ្លួនឯង ដែលជារូបកាយដ៏សែនអាម៉ាស់... **ពេលខ្ញុំសម្លឹងមើលមនុស្សនៅជុំវិញខ្លួន ដែលសុទ្ធតែជាមនុស្សមើលងាយមនុស្ស... ចិត្តខ្ញុំបានស្លាប់បាត់ទៅហើយ**...! ដង្ហើមខ្ញុំដែលកំពុងតែដកនេះ មិនដឹងដកដល់ពេលណាទេ! មិនដឹងដកដើម្បីអ្វីទេ!

ឱ! មនុស្សទាំងឡាយដែលនៅជុំវិញខ្លួនខ្ញុំ គ្មានម្នាក់ណាជាមិត្តខ្ញុំសោះ។ ខ្ញុំបានដើរចូលទៅក្រុមហ៊ុនដ៏ធំមួយ រួចសួរទៅសន្តិសុខម្នាក់ ក្រែងមានការងារអ្វីសមនឹងខ្ញុំធ្វើ តែត្រូវសន្តិសុខនោះបោះសម្តីដេញខ្ញុំ «ម្លែងមានសមត្ថភាពអី មកធ្វើការនៅក្រុមហ៊ុនធំអ៊ីចឹង? ឆាប់ចេញទៅ កុំឱ្យខូចសោភ័ណភាពក្រុមហ៊ុនគេ!»

**មនុស្សនៅក្នុងលោកនេះ មិនថាតែអ្នកមានទេដែលមាក់ងាយអ្នកក្រ អ្នកក្រដូចគ្នាក៏មាក់ងាយអ្នកណាក្រជាងខ្លួនមួយ**

**ជាន់ទៀតដែរ។** ខ្ញុំដើរមកដល់មុខភោជនីយដ្ឋានមួយ។ ឡាន របស់អ្នកមានកំពុងបើកចេញពីកន្លែងចត ស្រាប់តែអ្នកយាម ដែលកំពុងតែឱ្យសញ្ញាទៅឡាននោះ ទះខ្នងខ្ញុំមួយទំហឹងដៃ រួចស្តីឱ្យខ្ញុំទាំងខឹងសម្បា «អាឡប់គ្រឿងនេះ! ដើរគ្មានគ្រាប់ ភ្នែកមើលឡានទេអ្ហែះ?»

មនុស្សដែលអាណិតស្រលាញ់គ្នា នៅសល់តិចណាស់ សោតឯអ្នកដែលនៅសល់នោះ ក៏ស្រលាញ់អាណិតតែ អ្នកណាដែលគេមាននិស្ស័យជាមួយទៀត។ ទាល់តែខ្ញុំក្លាយ ជាមនុស្សម្នាក់ដែលគេមិនចូលចិត្ត ទើបខ្ញុំដឹងថា សង្គម មនុស្សជាសង្គមបែងចែកឋានៈដ៏គួរឱ្យខ្ពើម។ ហាងលក់ ទំនិញមួយដែលមានបិទអក្សរថា "ជ្រើសរើសបុគ្គលិក" តែ ពេលខ្ញុំចូលទៅសួរគេ... ខ្ញុំសួរពីរដងទើបគេងាកមកឆ្លើយនឹង ខ្ញុំទាំងធុញទ្រាន់ «រើសបានហើយ!»

មនុស្ស"ថ្លៃថ្នូរ"ទាំងឡាយ មិនចង់និយាយស្តីជាមួយខ្ញុំ ទេ។ គេមើលមកខ្ញុំប្រៀបដូចជាសត្វរុយមួយក្បាល។ ខ្ញុំចាប់ ផ្តើមស្អប់សង្គមមនុស្សខ្លាំងឡើង។ មនុស្សណាដែលស្អប់ ខ្ពើមខ្ញុំ ខ្ញុំក៏ស្អប់ខ្ពើមពួកគេវិញដូចគ្នា ហើយខ្ញុំស្អប់ខ្ពើមពួកគេ រហូតមិនចង់រស់នៅក្នុងស្ថាននេះជាមួយពួកគេទៀត។ ខ្ញុំគិត ថា បើគ្មានម្តាយខ្ញុំ ក្នុងលោកនេះខ្ញុំមិនដឹងថានឹងមានអ្នកណា ផ្សេងរាប់អានខ្ញុំទេ។ ប៉ុន្តែម្តាយខ្ញុំប្រាកដជាឃ្លាតពីខ្ញុំក្នុងពេល

ឆាប់ៗនេះហើយ។ តើខ្ញុំត្រូវរស់នៅម្នាក់ឯងបន្តទៀតយ៉ាងម៉េច?

នៅសល់ប្រហែលមួយរយម៉ែត្រទៀតប៉ុណ្ណោះ ខ្ញុំនឹងដើរដល់ផ្ទះកម្សត់របស់ខ្ញុំ។ ពេលឃើញខ្ញុំទៅដល់ ម្ដាយខ្ញុំប្រាកដជាសួរថា «ហេតុអ្វីយប់នេះយូរម្លេះ?» ខ្ញុំនឹងកុហកគាត់ដូចកាលពីម្សិលមិញទៀតថា «ការងាររវល់ពេក... សុំម៉ែកុំបារម្ភអី!» ឱ! សកម្មភាពគ្រប់យ៉ាងដែលខ្ញុំកំពុងធ្វើ សុទ្ធតែជាសកម្មភាពចំអកឱ្យជីវិតថោកទាបរបស់ខ្លួនតែប៉ុណ្ណោះ។

ពេលឈរនៅខាងមុខផ្ទះ ខ្ញុំខំសម្រួលទឹកមុខអស់សង្ឃឹមឱ្យទៅជាទឹកមុខមានសង្ឃឹម។ ខ្ញុំឈានជើងដើរយឺតៗចូលទៅក្នុងផ្ទះដែលងងឹតឈឹង។ ខ្ញុំនឹកថា ម្ដាយខ្ញុំប្រាកដជាកំពុងសំងំសម្រាន្តហើយ។ ខ្ញុំដុតចង្កៀងបំភ្លឺផ្ទះ។ ពន្លឺពណ៌ក្រហមតូចដែលខ្ញុំបានបង្កើត បាននាំកែវភ្នែកទាំងគូរបស់ខ្ញុំទៅមើលទីដំណេករបស់ម្ដាយខ្ញុំ។ ខ្ញុំទន់អស់ខ្លួនប្រាណ ស្លុតអស់ព្រលឹងវិញ្ញាណ។ ម្ដាយខ្ញុំគាត់មិនបានសម្រាន្តដូចការគិតរបស់ខ្ញុំទេ តែគាត់កំពុងតែហោះផុតជើងពីដី... ហោះទៅស្ថានសួគ៌ចោលរូបខ្ញុំជារៀងរហូត...

*ភ្នំពេញ សីហា ២០០៧*